# ព្រះពុទ្ធសាសនាសង្ខេប

សម្រាប់យុវជនសិក្សា

ភាគទី១

**ព្រះពោធិវង្ស ហួត - តាត**

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

រៀបរៀង

ព.ស. ២៤៩៥ គ.ស. ១៩៥៣

**បោះពុម្ពដោយ**

បណ្ណាគារ ត្រៃរតន៍

លេខ១៣៦អ៊ី០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៥៤២ គ.ស.១៩៩៩

# ពាក្យប្រារព្ធ

ចំនួនមួយឆ្នាំមកហើយ ខ្ញុំបាននឹកប្រារព្ធដល់ពួកយុវជន ក្នុងបច្ចុប្បន្ន-កាលនេះ ឃើញថាមាតាបិតាជីដូនជីតា ជាអ្នកកាន់ព្រះពុទ្ធសាសនា ចំណែកកូនចៅត្រឡប់ជាមានចិត្តរវាតចេញពីព្រះពុទ្ធសាសនាទៅវិញ ។ បានរំពឹងក្នុងរឿងនេះឃើញថា :

១. មកពីមាតាបិតា ចង់ឱ្យកូនចៅរបស់ខ្លួនបានចេះដឹងចំណេះវិជ្ជា ដែលឱ្យផលទាន់ភ្នែកឃើញ ភ្លេចគិតពីការដឹកនាំឱ្យកូនចៅកាន់ព្រះពុទ្ធសាសនាគិតតែឱ្យរៀនចំណេះអក្សរសាស្ត្រ នឹងវិទ្យាសាស្ត្រ តាមលោកនិយម ។

២. ព្រះសង្ឃក្នុងវត្តដែលមានទម្លាប់ជាអ្នកប្រៀនប្រដៅក្មេងៗ ឱ្យចេះដឹងផ្លូវព្រះពុទ្ធសាសនា តាំងពីបុរាណកាលមក ក៏ពុំមានឱកាសនឹងបំពេញមុខការនេះបាន ដោយហេតុពួកក្មេងៗខ្លះពុំអាស្រ័យនៅតាមវត្ត ឬបើមាននៅអាស្រ័យតាមវត្តខ្លះ ក៏ក្មេងទាំងនោះមានគំនិតបាញ់តម្រង់ទៅលើតែអក្សរសាស្ត្រ នឹងវិទ្យាសាស្ត្រតែម្យ៉ាង។

៣. សៀវភៅដែលទាក់ទងដោយព្រះពុទ្ធសាសនាដែលវិញ្ញូជន ជាបព្វជិតនិងគ្រហស្ថបានតែងឡើងទាំងប៉ុន្មាន សុទ្ធតែជាសៀវភៅមានសេចក្តីខ្ពស់ហួសថ្នាក់ដែលក្មេងៗពុំអាចសិក្សាបាន ។

ខ្ញុំបាននឹកឃើញដូច្នេះ ក៏បានផ្តងគំនិតគិតបម្រុងនឹងរកមធ្យោបាយដឹកនាំពួកយុវជនឱ្យចេះដឹង ឱ្យស្គាល់ព្រះពុទ្ធសាសនាតាំងពីថ្នាក់ទាបៗឡើងទៅ ។

***************

Websites: WatKhemaraRatanaram.org or WatKhmers.org

# ពាក្យប្រារព្ធ

ចំនួនមួយឆ្នាំមកហើយ ខ្ញុំបាននឹកប្រារព្ធដល់ពួកយុវជន ក្នុងបច្ចុប្បន្នកាលនេះ ឃើញថាមាតាបិតាជីដូនជីតា ជាអ្នកកាន់ព្រះពុទ្ធសាសនា ចំណែកកូនចៅត្រឡប់ជាមានចិត្តរវាតចេញពីព្រះពុទ្ធសាសនាទៅវិញ ។ បានរំពឹងក្នុងរឿងនេះឃើញថា :

១. មកពីមាតាបិតា ចង់ឱ្យកូនចៅរបស់ខ្លួនបានចេះដឹងចំណេះវិជ្ជា ដែលឱ្យផលទាន់ភ្នែកឃើញ ភ្លេចគិតពីការដឹកនាំឱ្យកូនចៅកាន់ព្រះពុទ្ធសាសនាគិតតែឱ្យរៀនចំណេះអក្សរសាស្ត្រ នឹងវិទ្យាសាស្ត្រ តាមលោកនិយម ។

២. ព្រះសង្ឃក្នុងវត្តដែលមានទម្លាប់ជាអ្នកប្រៀនប្រដៅក្មេងៗ ឱ្យចេះដឹងផ្លូវព្រះពុទ្ធសាសនា តាំងពីបុរាណកាលមក ក៏ពុំមានឱកាសនឹងបំពេញមុខការនេះបាន ដោយហេតុពួកក្មេងៗខ្លះពុំអាស្រ័យនៅតាមវត្ត ឬបើមាននៅអាស្រ័យតាមវត្តខ្លះ ក៏ក្មេងទាំងនោះមានគំនិតបាញ់តម្រង់ទៅលើតែអក្សរសាស្ត្រ នឹងវិទ្យាសាស្ត្រតែម្យ៉ាង។

៣. សៀវភៅដែលទាក់ទងដោយព្រះពុទ្ធសាសនាដែលវិញ្ញូជន ជាបព្វជិតនិងគ្រហស្ថបានតែងឡើងទាំងប៉ុន្មាន សុទ្ធតែជាសៀវភៅមានសេចក្ដីខ្ពស់ហួសថ្នាក់ដែលក្មេងៗពុំអាចសិក្សាបាន ។

ខ្ញុំបាននឹកឃើញដូច្នេះ ក៏បានផ្ដងគំនិតគិតបម្រុងនឹងរកមធ្យោបាយដឹកនាំពួកយុវជនឱ្យចេះដឹង ឱ្យស្គាល់ព្រះពុទ្ធសាសនាតាំងពីថ្នាក់ទាបៗឡើងទៅ ។

***************

Websites: WatKhemaraRatanaram.org or WatKhmers.org

# ព្រះពុទ្ធសាសនាសង្ខេប

## សម្រាប់ពួកយុវជន

## ពាក្យផ្ដើម

### សំដែងដោយបុគ្គលាធិដ្ឋាន

### ព្រះពុទ្ធ

មានលោកអាចារ្យមួយរូបនាម **ឧត្តមៈ** ជាអ្នកបង្រៀនព្រះពុទ្ធសា-សនាដល់ពួកយុវជន ។ មានកាល១ថ្ងៃ លោកអាចារ្យនោះបានសរសេរពាក្យ ថា **ពុទ្ធសាសនា** ជាអក្សរធំៗនៅលើក្ដារសរសេរ ហើយបានហៅក្មេង១នាក់ ឈ្មោះ **សុធន** ឱ្យមកមើលអក្សរនោះ ដោយមានបំណងចង់ពន្យល់ក្មេងនោះ នឹងក្មេងឯទៀតៗ ឱ្យបានយល់អំពីពាក្យថា **ពុទ្ធសាសនា** ។

**សុធន** - ក្រោកឡើង អានអក្សរនោះ ឮថា **ពុតៈសាសនា** ។

**ឧត្តមៈ** - ឯងអានខុសទេ មើលឱ្យច្បាស់ អក្សរនោះជា **តៈ** ឬជា **ធៈ** កុំឱ្យច្រឡំ អានម្ដងទៀតមកមើល ។

**សុ.** អានថា **ពុទ្ធៈសាស្នា** ។

**ឧ.** អើ. អានដូច្នេះទើបត្រូវ. ពាក្យនេះជាភាសាបាលី យល់ សេចក្ដីទេ **ពុទ្ធសាសនា** ប្រែថាដូចម្ដេច ?

**សុ.** ខ្ញុំព្រះករុណាមិនចេះប្រែទេ ប៉ុន្តែធ្លាប់ឮឪពុកម្ដាយ

Websites: WatKhemaraRatanaram.org or WatKhmers.org



ខ្ញុំព្រះករុណាគាត់ប្រាប់ថា សាសនាព្រះពុទ្ធ ។

ឆ. ឯងថានឹងក៏ត្រូវដែរ ប៉ុន្តែមិនបានសេចក្តីឱ្យច្បាស់ទេ ឪពុកម្តាយឯងបានប្រាប់ឯងទេ សាសនាគឺអ្វី ? ព្រះពុទ្ធគឺអ្វី ? ។

ស្នុ. ទានព្រោស គាត់មិនបានប្រាប់ទេ ។

ឆ. អើ. បើដូច្នេះឯងត្រូវប្រុងស្តាប់ អាត្មាប្រែហើយពន្យល់ថែម ទៀត សាសនា ប្រែថា ពាក្យប្រៀនប្រដៅ. ពុទ្ធ ប្រែថា អ្នកចេះដឹង ឬថា អ្នកត្រាស់ដឹង រួមពាក្យទាំងពីរបទនេះ ឱ្យទៅជាមួយបទថា ពុទ្ធសាសនា ប្រែថា ពាក្យប្រៀនប្រដៅ (របស់) អ្នកត្រាស់ដឹង ឬ (របស់) ព្រះពុទ្ធ ឯងស្តាប់បានទេ?

ស្នុ. ទានព្រោសស្តាប់បាន ប៉ុន្តែមិនទាន់យល់សេចក្តី ។ ខ្ញុំព្រះករុណាឆ្ងល់នឹងពាក្យថា ពុទ្ធ សូមសួរព្រះគុណម្ចាស់ ពុទ្ធ នេះប្រសិនបើសរសេរអក្សរ ពុ ប្រកបនឹង ត ថា ពុត ដូច្នេះបានឬទេ? ព្រោះអានទៅឮសម្លេងដូចគ្នា ព្រះពុទ្ធ ក៏ដូចជា ព្រះពុតដែរ ។

ឆ. យី ! អានាងនេះនៅល្ងង់ជ្រៅណាស់ទេតើ ! ណ្ហើយ ពាក្យថា សាសនា ទុកមួយអន្លើសិនចុះ ថ្ងៃនេះត្រូវពន្យល់ពាក្យមួយ បទថា ពុទ្ធ នេះ កុំអាលឱ្យហួស ។ ឯងថា ពុទ្ធ និង ពុត អានឮសម្លេងដូចគ្នាមែនហើយ ប៉ុន្តែខុសគ្នាឆ្ងាយណាស់ បើគេសរសេរថា ពុទ្ធ យ៉ាងនេះសំដៅយកលោកដែលជាអ្នកប្រាជ្ញធំបំផុត ដែលចេះដឹងជាងមនុស្សនិងទេវតា. បើសរសេរថា

Websites: WatKhemaraRatanaram.org or WatKhmers.org



ពុត្ត ដូច្នេះ សំដៅយកពុតត្បុតរបស់មនុស្សអាក្រក់ គេនិយាយថាមនុស្សមាន ពុត គឺមនុស្សដែលមានកិច្ចកលរបិញរបុញច្រើនយ៉ាង គេតែងនិយាយថាវា មិនឈឺសោះ ពុតធ្វើជាឈឺ, មានក្មេងខ្លះខិលខិលរៀនមិនទៅសាលា ពុតធ្វើ ជាឈឺ ដូច្នេះជាដើម ឯងយល់ឬទេ ?

ស្. ករុណា, ស្តាប់បានហើយ, ព្រះពុទ្ធនោះ ត្រូវសរសេរអក្សរ ពុ ប្រកប នឹង ទ មានជើង ធ, បើមនុស្ស ពុត្ត ត្រូវសរសេរ អក្សរ ពុ ប្រកប នឹង ត ។

ឥ. បើឯងយល់ហើយ ឯងពន្យល់គ្នាឯងឯទៀតៗឱ្យយល់ផង ទៅ កុំឱ្យសរសេរខុស ព្រោះពាក្យខ្មែរមានចំនួនច្រើន ដែលឮសូរសម្លេងដូចគ្នា ប៉ុន្តែត្រូវសរសេរផ្សេងពីគ្នា ដោយហេតុពាក្យខ្មែរយើងខ្លះជាភាសាបាលី ខ្លះ ជាភាសាសំស្ក្រឹត ខ្លះជាភាសាខ្មែរសុទ្ធ ពាក្យទាំងនោះអានឮសម្លេងដូចគ្នា ប៉ុន្តែសេចក្តីផ្សេងគ្នាស្រឡះ ដូចពាក្យថា សង់ សរសេរដូច្នេះ គឺសង់ផ្ទះ, ពាក្យមួយទៀតថា សង្ឃ ឮសម្លេងដូចគ្នា ប៉ុន្តែមិនមែនសង់ផ្ទះដូចគ្នាទេ គឺជា ព្រះសង្ឃ ដែលគេតែងគោរព ។ ហេតុនេះ, ឯងជាកូនខ្មែរអ្នករៀន ត្រូវឱ្យ ចេះសរសេរអក្សរខ្មែរឱ្យត្រឹមត្រូវ កុំសំគាល់ថាមិនបាច់រៀន ចេះតែសរសេរ ឱ្យឮតែសម្លេងទៅបានហើយ តែគិតយ៉ាងនេះ ហើយសរសេរតាមតែបាន ពួកអ្នកចេះដឹងទាំងឡាយ គេនឹងឱ្យឈ្មោះឯងថាមិនមែនជាកូនខ្មែរទេ គេទុក ឯងជាមនុស្សបង្ខិន ឬពង្រេចពង្រើលអក្សរសាស្ត្រសម្រាប់ជាតិខ្មែរ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ស៊ុ. ករុណា. ទានស្តាប់បានហើយ ខ្ញុំព្រះករុណានឹងប្រឹងរៀន ឱ្យដឹងច្បាស់លាស់ ហើយនឹងពន្យល់មិត្រភក្តិតទៅទៀត ។

ឆ. អើ. តពីនេះ អាត្មានឹងសួរឯងពី ព្រះពុទ្ធ ឯងដឹងទេ ព្រះពុទ្ធ នោះជាមនុស្ស ឬជាទេវតា សព្វថ្ងៃនៅឯណា ?

ស៊ុ. ទានប្រោស ខ្ញុំព្រះករុណាដឹងមិនច្បាស់ទេ ព្រោះព្រះពុទ្ធ នោះ ឃើញតែរូបនៅក្នុងវិហារ គេថ្វាយបង្គំគ្រប់គ្នា ទានមើលទៅ បើគេកោតខ្លាចសំពះថ្វាយបង្គំយ៉ាងនេះ ប្រហែលជាទេវតា ហើយមើលទៅ ។

ឆ. មិនមែនទេវតាទេ ព្រះពុទ្ធនោះជាមនុស្សពិតៗដូចយើងរាល់គ្នា ដែរ ប៉ុន្តែព្រះអង្គជាមនុស្សអស្ចារ្យប្លែកណាស់ ព្រះអង្គមានគុណជាអនេក ឥតមានអ្នកណាស្មើ បានជាគេគោរពកោតខ្លាចថ្វាយបង្គំ ។ ព្រះពុទ្ធនោះ ទ្រង់បរិនិព្វានទៅហើយ ប៉ុន្តែគេសាងព្រះរូបទុកជាទីរលឹក សម្រាប់គោរព បូជាថ្វាយបង្គំ ។

ស៊ុ. ទានប្រោស. ព្រះពុទ្ធ ទ្រង់បរិនិព្វានពីអង្កាល់ យូរហើយ ឬ ?

ឆ. ព្រះពុទ្ធ ទ្រង់បរិនិព្វាន យូរណាស់ហើយ កាលបរិនិព្វាន នៅថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ មុនពុទ្ធសករាជ១ថ្ងៃ គិតមកដល់ ឥឡូវនេះ បាន ២៥៣៨ឆ្នាំហើយ ។

ស៊ុ. ទានប្រោស. គួរឱ្យអស្ចារ្យណាស់ ព្រះពុទ្ធបរិនិព្វានបាត់ទៅ រាប់ពាន់ឆ្នាំហើយ គេនៅតែចាំព្រះនាម នាំគ្នាគោរព ។ ទានប្រោស. ព្រះពុទ្ធ នោះ កាលព្រះអង្គកើតឡើងដំបូង ឪពុកម្តាយឱ្យឈ្មោះថាព្រះពុទ្ធៗ

Websites: WatKhemaraRatanaram.org or WatKhmers.org



យ៉ាងហ្នឹងតែម្តង ឬក៏មានឈ្មោះផ្សេង ទេ ?

ឆ. ឱ ! សុធននេះហៅពេញជាមិនដឹងរឿងពុទ្ធប្បវត្តិយ៉ាងជាក់ច្បាស់សោះ ប៉ុន្តែចេះសួរគួរឱ្យអាត្មាចង់និយាយប្រាប់ ឯងប្រុងស្តាប់ណា:! **ព្រះពុទ្ធ**នោះ កាលកើតឡើងដំបូង គេឱ្យឈ្មោះថា **សិទ្ធត្ថ**. ប៉ុន្តែគេនិយាយ ថា គេថ្វាយព្រះនាម, ថាព្រះបិតាព្រះមាតាព្រះពុទ្ធ, គេមិនដែលថាឈ្មោះ, ថាឪពុកម្តាយព្រះពុទ្ធទេ ព្រោះព្រះអង្គជាក្សត្រិយ៍ ។

សុ. ទានព្រោស, បើមុនដំបូងមានព្រះនាមថា **សិទ្ធត្ថ**ទេ ចុះហេតុដូចម្តេច ក៏បានជាគេហៅថា **ព្រះពុទ្ធ** ដូច្នេះទៅវិញ ?

ឆ. ឱ ! សុធនអើយ រឿង**សិទ្ធត្ថ** ដែលបានទៅជា **ព្រះពុទ្ធ** នោះ មានហេតុគួរឱ្យអស្ចារ្យណាស់ ល្មើយអាត្មានិយាយប្រាប់ឱ្យវែងបន្តិច ឯងចាំស្តាប់ឱ្យមែនទែនណា:! **សិទ្ធត្ថ**នោះ កាលនៅពីកុមារ បានរៀនចំណេះវិជ្ជាដូចឯងរាល់គ្នាដែរ ប៉ុន្តែរៀនពូកែណាស់ ឈ្លាសវៃឥតមានអ្នកណាស្មើ ដល់ធំឡើងព្រះជន្ម ១៦ឆ្នាំ មានព្រះអគ្គមហេសី(ប្រពន្ធ) ព្រះនាមព្រះនាង **ពិម្ពា** ជួនកាលគេហៅថា **យសោធរា**. ព្រះបិតាទ្រង់អភិសេកឱ្យសោយរាជ្យតំណាងព្រះអង្គ. មានព្រះរាជបុត្រ១នាម **រាហុល** ។ លុះ**ព្រះសិទ្ធត្ថ** ដល់ព្រះជន្ម ២៩ឆ្នាំ ស្តេចទៅក្រសាលឯឱទ្យាន បានទតឃើញ មនុស្សចាស់ មនុស្សឈឺ នឹងមនុស្សស្លាប់ បានជ្រាបច្បាស់ដោយសារគេក្រាបទូល ក៏គិតរំពឹងពិចារណា ជ្រាបច្បាស់ថាខ្លួនព្រះអង្គគង់តែនឹងចាស់ ឈឺ ស្លាប់ដូច្នោះដែរ

Websites: WatKhemaraRatanaram.org or WatKhmers.org



ទើបមានព្រះទ័យតក់ស្លុតរន្ធត់ ឥតរីករាយសប្បាយសោះ ក៏ត្រឡប់មកវិញ ។ ដល់ថ្ងៃក្រោយ ស្តេចទៅម្តងទៀតបានឃើញអ្នកបួសបានជ្រាប ដោយមានគេក្រាបទូលថា អ្នកបួសនេះគេស្វែងរកធម៌ដែលឥតចាស់ ឈឺ ស្លាប់ ។ ព្រះអង្គក៏សប្បាយព្រះទ័យនឹកថា នឹងបួសតាមបែបនេះឱ្យបាន ព្រោះនៅក្នុងគេហដ្ឋានដូចសព្វថ្ងៃនេះ មុខជានឹងរកធម៌មិនចាស់ មិនឈឺ មិនស្លាប់នោះមិនបានទេ ។ តពីនោះមិនយូរប៉ុន្មាន ព្រះអង្គក៏ចេញទៅបួសក្នុងវេលារាត្រី បួសរួចហើយខំប្រឹងប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ យ៉ាងតឹងបំផុត ឥតមានអ្នកណាធ្វើតាមបាន អស់ប្រាំមួយឆ្នាំគត់. ដល់ទីបំផុតព្រះអង្គបានចំរើនសម្មាធិកម្មដ្ឋាន កើតឈានសមាបត្តិ បានកំចាត់កិលេសធម៌ គឺគ្រឿងសៅហ្មងអស់ពីសន្តាន បានសម្រេចនូវវិជ្ជា គឺការចេះដឹងសព្វគ្រប់ ទើបហៅថាព្រះអង្គបានត្រាស់ ។ តាំងពីនោះមក គេនាំគ្នាហៅព្រះបាទ **សិទ្ធត្ថ** នោះ ថា **ព្រះពុទ្ធ**ៗ ជាប់តមកដល់ឥឡូវនេះ ។

**ស**. ទានប្រោស. ចុះកាលព្រះអង្គបានត្រាស់នោះ ព្រះអង្គត្រាស់ពីអង្កាល់? ខ្ញុំព្រះករុណាចង់ដឹងណាស់ ។

**ឆ**. កាលព្រះអង្គបានត្រាស់ដឹង នៅថ្ងៃ១៥កើត ខែពិសាខឆ្នាំរកា មុនពុទ្ធសករាជ៤៥ឆ្នាំ ។ កាលព្រះពុទ្ធទ្រង់ប្រសូតក៏នៅថ្ងៃ១៥កើតខែពិសាខដែរ មុនពុទ្ធសករាជ៨០ឆ្នាំ ទាំងកាលបរិនិព្វានក៏នៅថ្ងៃ១៥កើត ខែពិសាខដូចគ្នាមុនពុទ្ធសករាជ១ថ្ងៃ ។ ហេតុនេះបានជាអ្នកកាន់ព្រះពុទ្ធសាសនាគ្រប់ប្រទេសក្នុងលោកសព្វថ្ងៃ តែដល់ថ្ងៃ១៥កើត ខែពិសាខ គេនាំគ្នាទៅប្រជុំនៅ

Websites: WatKhemaraRatanaram.org or WatKhmers.org



ទីវត្តអារាម គោរពបូជារំលឹកដល់គុណព្រះពុទ្ធ ហៅថាបុណ្យ **វិសាខបូជា** ឯងក៏អាចនឹកឃើញដែរហើយ នៅថ្ងៃ១៥កើតខែពិសាខនេះ រាជការបានអនុញ្ញាតឲ្យក្រសួងរាជការ នឹងសាលារៀនទាំងអស់ ឈប់ធ្វើការ ឈប់រៀន ដើម្បីឲ្យអ្នករាជការ នឹងសិស្សក្នុងសាលារៀន នាំគ្នាទៅគោរពដល់គុណ **ព្រះពុទ្ធ** ជាបរមគ្រូតាំងចិត្តរលឹកដល់ថ្ងៃដែលព្រះអង្គប្រសូត, បានត្រាស់ដឹងនឹងចំពោះថ្ងៃបរិនិព្វាន។ អានាងឯងចាំណា:!

ស្មុ. ទានព្រោស, ស្ដាប់បានហើយ ចាំហើយ ។

ឌ. បើស្ដាប់បានហើយ អាត្មាចង់សួរឯងតទៅទៀត ឯងដឹងហើយឬនៅ **ព្រះពុទ្ធ**ជាជាតិអ្វី ? ឪពុកម្ដាយឯង ដែលនិយាយប្រាប់ដែរឬទេ ? ។

ស្មុ. ទានព្រោស, ខ្ញុំព្រះករុណាមិនដឹងទេ ទាំងឪពុកម្ដាយខ្ញុំព្រះករុណាក៏មិនដែលបាននិយាយប្រាប់ទេ ប៉ុន្តែ**ព្រះពុទ្ធ**នោះ ហេតុម្ដេចក៏ព្រះគុណម្ចាស់សួរដូច្នេះ? ក្រែង**ព្រះពុទ្ធ**នោះ ជាជាតិខ្មែរយើង នៅក្នុងប្រទេសខ្មែរយើងហ្នឹងដែរឬ ? ត្រង់ព្រះមាតា:បិតា**ព្រះពុទ្ធ**នោះ ខ្ញុំព្រះករុណាឥតដឹងទេ ។

ឌ. អើសុធន, ឯងនៅក្មេងណាស់ ល្មមឯងមិនដឹងមែន, ឪពុកម្ដាយឯងដែលមិនដែលនិយាយប្រាប់ ប្រហែលជាគាត់មិនដឹងដែរទេដឹង មើលទៅ! ណ្ហើយចុះឯងចាំស្ដាប់ អាត្មានិយាយប្រាប់ **ព្រះពុទ្ធ**នោះ មិនមែនជាជាតិខ្មែរនៅក្នុងប្រទេសខ្មែរយើងនេះទេ ព្រះអង្គមានជាតិជាក្សត្រិយ៍ ដូចអាត្មាបាននិយាយប្រាប់ឯងពីខាងដើមរួចម្ដងហើយ តើឯងមិនចាំទេឬ មានវង្សជា**គោតម:**

Websites: WatKhemaraRatanaram.org or WatKhmers.org



គឺវង្ស ឬសែព្រះអាទិត្យ មានត្រកូលជា **សាក្យៈ** ជាពួកមនុស្ស **អរិយកៈ** ក្នុងប្រទេសកណ្តាលដែលហៅថា **មជ្ឈិមប្រទេស** ឬ **មធ្យមប្រទេស** ។ ព្រះបិតាទ្រង់ព្រះនាម **សុទ្ធោទនៈ** ជាព្រះចៅក្រុង**កបិលវត្ថុ** ឬ**កបិលព័ស្តុ** ក្នុងដែន**សក្កៈ**. ព្រះមាតាទ្រង់ព្រះនាម **មហាមាយា** ។ អាត្មានិយាយប្រាប់ខ្លីៗ ឱ្យឯងងាយស្តាប់ ឯងស្តាប់បានឬទេ ។

**សុ.** ទានព្រោស , ស្តាប់បាន , ប៉ុន្តែនៅមានឆ្ងល់ត្រង់ពាក្យថា **មជ្ឈិមប្រទេស**ៗនោះនៅឯណាសព្វថ្ងៃ ក្រុង**កបិលវត្ថុ** នឹងដែន**សក្កៈ** ក៏មិនដែលឮខ្ញុំព្រះករុណាធ្លាប់បានរៀនផែនទីក្នុងសាលាដែរ មិនដែលឮលោកគ្រូក្នុងសាលាប្រាប់សោះ. សូមទានពន្យល់ឱ្យខ្ញុំព្រះករុណាបានដឹងផង ។

**ធ.** ឱសុធន! ឈ្មោះប្រទេសនឹងឈ្មោះទីក្រុងនោះ សព្វថ្ងៃនេះប្រែប្រួលអស់ទៅហើយ ព្រោះតាំងពីសម័យនោះមកដល់ឥឡូវ យូរអង្វែងរាប់ពាន់ឆ្នាំទៅហើយធ្វើម្តេចនឹងនៅដូចដដែល ប៉ុន្តែបើទុកជាប្រែប្រួលយ៉ាងណា ក៏គង់តែពួកអ្នកចេះដឹង គេនៅតែដឹងបានជាក់ច្បាស់ផងឯពាក្យថា **មជ្ឈិមប្រទេស** គឺប្រទេសកណ្តាលនោះ ជាភាគផែនដីដែលជិតជាប់គ្នានឹងប្រទេសឥណ្ឌាសព្វថ្ងៃនេះ. ដែនសក្កៈនោះ សព្វថ្ងៃក្លាយឈ្មោះទៅជា**នេប៉ាល**. ឯទីក្រុង**កបិលវត្ថុ**នោះ ខ្មែរយើងហៅថាក្រុង**កបិលពស្តុ** សព្វថ្ងៃនេះគេហៅថាក្រុង **កប្ឋម័ណ្ឌុ** ។ ម៉េចឯងយល់ទេ ?

**សុ.** ទានព្រោសយល់ហើយ បើថាឥណ្ឌា. នេប៉ាល. កម្ពម័ណ្ឌូ យ៉ាងនេះ

Websites: WatKhemaraRatanaram.org or WatKhers.org



លោកគ្រូក្នុងសាលាធ្លាប់បង្រៀនដែរ ដោយមានឈ្មោះក្នុងផែនទី លោកស្រាប់ ប៉ុន្តែក្នុងផែនទីត្រង់ពាក្យថា **ឥណ្ឌា** ឃើញអក្សរអឺរ៉ុបថា INDIA គួរអានថា **ឥណ្ឌា** គឺមានសម្លេងជាស្រៈ អិរ៉ា មិនមែនស្រៈ អៀទេ ចុះម៉េចក៏ខ្មែរសរសេរជា **ឥណ្ឌា** ទៅវិញ ?

ឆ. ឱ! ឯងថាហ្នឹងត្រូវហើយ ប៉ុន្តែដែលខ្មែរយើងសរសេរជា **ឥណ្ឌា** នេះគឺសរសេរតាមទម្លាប់ដែលធ្លាប់តែប្រើមកដូច្នេះជាយូរណាស់ហើយ កែប្រែពុំកើត ។

សុ. ទានព្រោស, ចុះ **នេប៉ាល** ប្រែថាម៉េច? **កាដ្ឋមណ្ឌុ** ប្រែថាម៉េច?

ឆ. ឱ! ឯងសួរនេះហួសថ្នាក់ចំណេះរបស់ឯងជាកុមារទៅហើយ ប៉ុន្តែដោយសារឯងចង់ដឹង អាត្មាត្រូវតែប្រាប់ **នេប៉ាល** ប្រែថា "ប្រទេសរក្សាសណ្ដាប់ធ្នាប់ល្អរបស់ខ្លួនទុកមិនឱ្យបាត់", **កាដ្ឋមណ្ឌុ** គេបំផ្លែងឱ្យស្រួលមាត់ហៅ មកពីពាក្យដើមថា **កាដ្ឋមណ្ឌប** ប្រែថា "ក្រុងមានដំណាក់ប្រាសាទសុទ្ធតែធ្វើដោយឈើខ្លឹមជាប់បានយូរអង្វែង" ឬប្រែកាត់ខ្លីថា "ក្រុងផ្ទះឈើ" ព្រោះប្រទេសនេប៉ាលនោះ មានឈើខ្លឹមមួយប្រភេទ ជាឈើលេខមួយមានសាច់ជាប់ណាស់ ប្រើបានយូរមិនពុកស្មើរប្រណាំងនឹងថ្មបាន ។

សុ. ព្រះគុណបានពន្យល់ពាក្យទាំងនេះ នាំឱ្យខ្ញុំព្រះករុណាបានយល់បានចេះកាន់តែច្រើន អរព្រះគុណពេកណាស់ ។

ឆ. សុធន រឿងព្រះពុទ្ធនេះ នៅមានពិស្ដារវែងណាស់ អាត្មានិយាយ

Websites: WatKhemaraRatanaram.org or WatKhmers.org



ប្រាប់ចំពោះតែរឿងខ្លីៗ ឱ្យល្មមដល់ការចេះដឹងរបស់ឯងដែលនៅក្មេង, ដល់ឯងធំឡើង ត្រូវសិក្សាតទៅទៀត ដើម្បីឱ្យបានចេះដឹងរឿងព្រះពុទ្ធឱ្យជាក់ច្បាស់ ព្រោះក្នុងប្រទេសយើងនេះ ប្រជាជនស្ទើរតែគ្មានសល់ម្នាក់ សុទ្ធសឹងតែកាន់ព្រះពុទ្ធសាសនាទាំងអស់ ឪពុកម្ដាយឯងក៏កាន់ព្រះពុទ្ធសាសនាដូចប្រជាជនឯទៀតដែរ ។ ខ្លួនឯងជាកូន ត្រូវកាន់ព្រះពុទ្ធសាសនាតាមសណ្ដាប់វង្សត្រកូលរបស់ឪពុកម្ដាយខ្លួន, ដូច្នេះមុនដំបូងត្រូវតែឯងនឹងមិត្រភ័ក្ដឯងទាំងអស់គ្នា រៀនឱ្យចេះរឿងព្រះពុទ្ធសិន រួចសឹមរៀនរឿងសាសនាតទៅទៀត ដើម្បីនឹងបានកាន់តាមលំអានព្រះពុទ្ធសាសនាឱ្យត្រឹមត្រូវ, ឯងរាល់គ្នានឹងបាននាមពិសេសហៅថា ពុទ្ធសាសនិក ប្រែថា "អ្នកកាន់ព្រះពុទ្ធសាសនា" ឬ "អ្នកពុទ្ធសាសន៍" ឬថា **ពុទ្ធមាមកៈ** ប្រែថា "អ្នកគោរពរាប់អានព្រះពុទ្ធជាបរមគ្រូរបស់ខ្លួន" ដូចជាអាត្មានេះឯង ឬដូចជាឪពុកម្ដាយឯងរាល់គ្នាដែរ ។ ក្នុងថ្ងៃនេះសុធនឯង នឹងគ្នាឯងទាំងអស់គ្នា រៀនរឿងព្រះពុទ្ធត្រឹមប៉ុណ្ណឹងចុះ ព្រោះដល់ពេលល្មមឈប់សម្រាក់ហើយ ប៉ុន្តែមុននឹងចេញពីនេះទៅ ឯងទាំងអស់គ្នារៀនពាក្យថ្វាយបង្គំព្រះពុទ្ធយ៉ាងខ្លីបន្តិចសិន អាត្មាចងជាពាក្យកាព្យបទព្រហ្មគីតិ ឱ្យងាយទន្ទេញដូចខាងក្រោមនេះ :

យើងខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ
ទ្រង់មានប្រាជ្ញាមុត ប្រសើរផុតលើសលោកា ។
ទ្រង់ផ្ចាញ់មារចង្រៃ ពលច្រើនក្រៃឱ្យបរា-

Websites: WatKhemaraRatanaram.org or WatKhmers.org



ជ័យក្រោមពោធិ៍ព្រឹក្សា ហើយបានត្រាស់ជាព្រះពុទ្ធ ។
យើងខ្ញុំសូមព្រះអង្គ ជួយស្រោចស្រង់ឱ្យបានផុត
ចាកទុកឃាំងឆាប់ឆុត ពីឥឡូវនេះទៅហោង ។

ស្ទ. ទានប្រោស ខ្ញុំព្រះករុណាទាំងអស់គ្នាបានកត់ហើយ នឹងយកទៅទន្ទេញឱ្យចាំ ដល់ថ្ងៃស្អែក ខ្ញុំព្រះករុណាទាំងអស់គ្នា នឹងនាំគ្នាមកកាន់សំណាក់ព្រះគុណម្ចាស់ ដើម្បីនឹងសិក្សាតទៅទៀត ។

ឆ. អើ ទៅសិនចុះ! សុខិតា ហោថ ! សូមឱ្យសុខសប្បាយរាល់គ្នាណា:!

សុធននឹងក្មេងទាំងអស់គ្នាទទួលពរថា ព្រះករុណា! សាធុ! សាធុ!

Websites: WatKhemaraRatanaram.org or WatKhmers.org

# ព្រះធម៌

ដល់ពេលបង្រៀនរឿង **ព្រះពុទ្ធសាសនា** លោកធម្មធរៈបានផ្ដើមនិយាយនឹងពួកក្មេងៗជាសិស្សថា :

ពីម្សិលមិញ អាត្មាបានបង្រៀនរឿងព្រះពុទ្ធសាសនា ប៉ុន្តែបានស្លេះទុកនូវពាក្យថា **សាសនា**សិន បានពន្យល់ដល់សុធន នឹងឯងទាំងអស់គ្នា ចំពោះតែពាក្យថា**ព្រះពុទ្ធ**ប៉ុណ្ណោះ។ ឥឡូវថ្ងៃនេះយើងត្រូវផ្ដើមរៀនរឿងសាសនាតទៅទៀត ។ លោកធម្មធរៈ បានសរសេរអក្សរធំៗថា **សាសនា** នៅលើក្ដារខៀបញ្ឈរ ហើយបានហៅក្មេង១នាក់ឈ្មោះកុញ្ញរ ឱ្យមកមើលអក្សរនោះ។ កុញ្ញរក្រោកឡើងអានថា **សាស្នា** ។

**ធម្មធរៈ** .អើ កុញ្ញរឯងអានត្រូវហើយ ប៉ុន្តែត្រូវសរសេរថា**សាសនា** កុំតម្រួតគ្នាជា **ស្នា** ព្រោះពាក្យនេះជាភាសាបាលី សំដីខ្មែរយើង**អាន**ញាប់ណាស់ទៅ ឮសូរដូចជាតម្រួតគ្នា, ក៏ដូចជាពាក្យថា ឃោសនា, ទេសនា, វាសនា, ជាដើមនេះដែរ គេអានថាឃោស្នា, ទេស្នា, វាស្នា តាមទម្លាប់ស្រួលមាត់, ក្នុងលោកទាំងមូល ទុកជាភាសាណាក៏មានការអានផ្សេងគ្នា ពីអក្សរដែលសរសេរខ្លះ ដូចជាភាសាខ្មែរយើងដែរ ។ ឯងយល់ទេ ពាក្យថា **សាសនា** ពីម្សិលមិញអាត្មាបានប្រែឱ្យស្ដាប់រួចហើយ ឯងថាទៅមើល ចាំឬទេ ?

**ភ្ញ**. ទានព្រោស, ក្រែងប្រែថា "ពាក្យប្រៀនប្រដៅ" ដូច្នេះ ឬមិនមែនទេ ?

Websites: WatKhemaraRatanaram.org or WatKhmers.org



ឆ. មែនហើយ, ប៉ុន្តែឯងកុំច្រឡំឱ្យសោះពាក្យថា សាសនា ដែលប្រែថា "ពាក្យប្រៀនប្រដៅ" នោះមិនទាន់ប្រាកដជាពាក្យប្រៀនប្រដៅរបស់លោកណាអ្នកណានៅឡើយទេ លុះតែមានពាក្យដទៃផ្សំមកទៀតទើបប្រាកដបើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គេត្រូវនិយាយថា"សាសនាព្រះពុទ្ធ" តែដែលថាដូច្នេះតាមភាសាខ្មែរ បើតាមរបៀបបាលីគេថាពុទ្ធសាសនា ឬព្រះពុទ្ធសាសនា "ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ" ឯងយល់ហើយឬ?

គ្រូ. ទានព្រោស, ត្រង់ពាក្យថាសាសនា ផ្សំនឹងពុទ្ធ ជាពុទ្ធសាស-នានោះយល់ហើយ ប៉ុន្តែមិនយល់សេចក្តីពុទ្ធសាសនា ដែលប្រែថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះ តើប្រៀនប្រដៅដូចម្តេច សូមមេត្តាពន្យល់ឱ្យទាន ។

ឆ. កុញ្ញរ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មានច្រើនណាស់ អាត្មានិយាយឱ្យឯងស្តាប់មិនអស់ទេ ព្រះពុទ្ធត្រាស់ហើយគង់នៅបាន៤៥ឆ្នាំ ក៏ចូលបរិនិព្វានទៅ ។ ក្នុងរវាង៤៥ឆ្នាំនោះ ព្រះអង្គទេសនាប្រដៅពន្យល់សព្វសត្វលោក, ពាក្យដែលព្រះអង្គទេសនាប្រដៅពន្យល់ទាំងប៉ុន្មាន ហៅថាព្រះពុទ្ធសា-សនា ទាំងអស់ ប៉ុន្តែគោលរបស់ពុទ្ធសាសនានោះ បើរួបរួមដោយសង្ខេបមាន៣យ៉ាងគឺ :

១- ទ្រង់ប្រដៅថា "កុំឱ្យធ្វើអំពើអាក្រក់"

២- ទ្រង់ប្រដៅថា "ឱ្យធ្វើអំពើល្អ"

៣- ទ្រង់ប្រដៅថា "ឱ្យដុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាត"

Websites: WatKhemaraRatanaram.org or WatKhmers.org



ពាក្យទាំងបីខនេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ, ព្រះពុទ្ធអង្គណាក៏មិនដែលខានប្រដៅដូចខាងលើនេះដែរ។

គោលទាំង៣យ៉ាងនោះ ក្នុងគម្ពីរលោករៀបរៀងជាភាសាបាលីថា:

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**

**សចិត្តបរិយោទបនំ ឯតំពុទ្ធាន សាសនំ**

(សេចក្តីប្រែដូចខាងលើ)

ហេតុនេះ កុមារឯងនឹងគ្នាឯងទាំងអស់គ្នា ត្រូវកត់យកទៅទន្ទេញឱ្យចាំមាត់។

**កុ.** ទានប្រោស, កត់ហើយ, ខ្ញុំព្រះករុណានឹងទន្ទេញឱ្យចាំ ព្រោះពេញចិត្តណាស់ ។

**ឥ.** អើកុមារ, ត្រង់ខទី១ពាក្យថា "អំពើអាក្រក់" នេះជាពាក្យខ្មែរបើជាពាក្យបាលីវិញ គេហៅបានច្រើនយ៉ាងថា "បាបឬបាបកម្ម" ក៏បាន,ថា "អកុសល ឬអកុសលកម្ម" ដូច្នេះក៏បាន ។ ត្រង់ខទី២ពាក្យថា"អំពើល្អ"បើជាពាក្យបាលីថា "បុណ្យ ឬបុញ្ញកម្ម" ក៏បាន, ថា "កុសល ឬកុសលកម្ម" ដូច្នេះក៏បាន។ ឯងកត់យកទៅទន្ទេញឱ្យចាំ ឱ្យចេះពាក្យច្រើនយ៉ាងទើបងាយស្តាប់គេនិយាយធម៌ ងាយស្តាប់លោកសំដែងធម៌ ។

**កុ.** ទានប្រោស, ខ្ញុំព្រះករុណាចេះតែកត់ត្រាយកទៅទន្ទេញតាម ព្រះគុណម្ចាស់, ប៉ុន្តែក្នុងរឿងនេះ ខ្ញុំព្រះករុណាឆ្ងល់ណាស់, ព្រះគុណពន្យល់ប្រាប់មុនដំបូងពីព្រះពុទ្ធសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ រហូតមកដល់បាប

Websites: WatKhemaraRatanaram.org or WatKhmers.org



បុណ្យក៏នៅក្នុងរឿងជាមួយគ្នាដែរ. ឥឡូវព្រះគុណប្រាប់ថា បើចេះពាក្យអស់នេះច្រើនទៅ នាំឱ្យងាយស្ដាប់ធម៌. ទានព្រោស. បើចេះតែពាក្យខាងព្រះពុទ្ធសាសនាទេ ចុះហេតុដូចម្ដេច ក៏ទៅជាងាយស្ដាប់ធម៌ទៅវិញ? ចុះពុទ្ធសាសនានឹងធម៌ផ្សេងគ្នាដូចម្ដេច ?

ឆ. ឱ កុញ្ញរ គួរឆ្ងល់ដែរ. អាត្មាមិនបានពន្យល់ពីខាងដើមឱ្យហើយ ឯងកុំឆ្ងល់. ដូចគ្នាទេ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគឺ ព្រះធម៌ ព្រះធម៌ក៏គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនុះដែរ ។ ព្រះពុទ្ធត្រាស់ដឹងឡើងសំដែងធម៌ ប្រៀនប្រដៅមនុស្ស ទេពតា ឱ្យស្គាល់បុណ្យ បាប គុណ ទោស ខុស ត្រូវគ្រប់យ៉ាង ។ ម៉េចស្ដាប់បានទេ?

កុ. ទានព្រោស. ស្ដាប់បានហើយ. ខ្ញុំព្រះករុណាសូមព្រះគុណមេត្តាពន្យល់អំពីព្រះពុទ្ធសាសនាត្រង់ខទី១ឱ្យទាន ដូចម្ដេចហៅថា អំពើអាក្រក់? ហេតុដូចម្ដេច បានជាព្រះពុទ្ធជាម្ចាស់ប្រដៅមិនឱ្យធ្វើអំពីអាក្រក់?

ឆ. ដែលហៅថាអំពើអាក្រក់នោះ គឺអំពើដែលមិនត្រូវតាមគន្លងធម៌ ឬអំពើដែលខុសនឹងច្បាប់ក្នុងលោកិយ ជាអំពើដែលធ្វើឱ្យអ្នកដទៃខឹងអន់ចិត្ត. ដូចខ្ទនកុញ្ញរឯងខឹងនឹងក្មេងឯទៀត ហើយវាយគេឱ្យមានស្លាកស្នាម. ជេរគេដល់ម្ដាយឪពុក ឬចងគំនុំរករឿងគេទៅថ្ងៃមុខ. អំពើទាំងអស់នេះ សុទ្ធតែអាក្រក់ព្រោះនឹងនាំឱ្យកុញ្ញរឯងបានសេចក្ដីលំបាក ដោយហេតុត្រូវគេវាយ ឬគេជេរកុញ្ញរឯងវិញ គេចងគំនុំរករឿងធ្វើឱ្យកុញ្ញរឯងបានលំបាកវិញពុំខាន . មួយទៀត

Websites: WatKhemaraRatanaram.org or WatKhmers.org



ដូចជាកុញ្ញរឯងឃើញសត្វតូចតាច ហើយកុញ្ញរឯងឥតអាណិតវាសោះ ទៅទះឬវាយសម្លាប់វាយ៉ាងនេះ ក៏ហៅថាអំពើអាក្រក់, ឬកុញ្ញរឯងទៅលួចយកដងចាំកកា ឬខ្មៅដៃរបស់ក្មេងដូចគ្នាក្នុងសាលារៀន នេះក៏ហៅថាអាក្រក់ដែរ ពុំនោះឯងខ្ជិលរៀន កុហកភូតភរគេថាមានធុរៈ អំពើទាំងនេះហៅថា អាក្រក់ទាំងអស់, បើឯងធ្វើអាក្រក់យ៉ាងនេះហើយ ឯងនឹងត្រូវទទួលទុក្ខទោស ឬទណ្ឌកម្មអំពីម្ដាយឪពុកឯងខ្លះ អំពីគ្រូបង្រៀនខ្លះពុំខាន ។ ពុំនោះសោត ដូចកាលកុញ្ញរឯងទៅសាលារៀន ទៅមិនទាន់ម៉ោង ឬទៅទាន់ម៉ោងដែរ ប៉ុន្តែចេះតែប្រទ្បែងគ្នាលេងយ៉ាងនេះ ហៅថាធ្វើខុសច្បាប់ក្នុងសាលា, ការខុសច្បាប់នេះ ហៅថាអំពើអាក្រក់, ខ្លួនឯងមុខជាត្រូវទទួលទណ្ឌកម្មពុំខាន ។

នែកុញ្ញរ, អំពើអាក្រក់មានតាំងពីតូចៗរហូតដល់ទៅធំៗ អ្នកណាធ្វើអាក្រក់តូច ត្រូវទទួលទុក្ខទោសក៏តូច, អ្នកណាធ្វើអាក្រក់ធំ ត្រូវទទួលទុក្ខទោសក៏ធំ, ដោយហេតុនេះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រៀនប្រដៅមិនឱ្យធ្វើតាំងពីអំពើអាក្រក់ក៏តូចតាចឡើងទៅ ព្រោះព្រះអង្គចង់ឱ្យមនុស្សសត្វរាល់រូបបានសេចក្ដីសុខ ។ ម៉េច កុញ្ញរស្ដាប់បានទេ? យល់ទេ ?

ក្មុ. ទានប្រោស, យល់ហើយ ។ ចុះត្រង់ខទី២ ថាឱ្យធ្វើអំពើល្អ ដូចម្ដេចទៅ? សូមមេត្តាពន្យល់ឱ្យទានបន្តិចតទៅទៀត ។

ឥ. មិនបាច់ពន្យល់ទេ កុញ្ញរ, អំពើល្អនោះផ្សេងដទៃពីអំពើអាក្រក់, ឯងគិតទៅឆាប់យល់ទេ ដូចជាឯងស្គាល់ងងឹត គង់ស្គាល់ភ្លឺ, ស្គាល់ពណ៌ខ្មៅ គង់

Websites: WatKhemaraRatanaram.org or WatKhmers.org



ស្គាល់ពណ៌ស. ស្គាល់វែង គង់ស្គាល់ខ្លី ឯអំពើអាក្រក់ បើឯងបានស្គាល់ហើយ គង់យល់ដល់អំពើល្អ ដូចសេចក្ដីខាងដើមដែលអាត្មាបានពន្យល់ថា ឯងទៅវាយគេ សម្លាប់គេ លួចគេជាដើម ហៅថាឯងធ្វើអំពើអាក្រក់. ឯចំណែកអំពើល្អនោះ ផ្ទុយគ្នាទៅវិញ គឺខ្លួនកុញ្ញរឯងខ្លាចចិត្តគេ ឬអាណិតគេ មិនវាយគេ មិនជេរគេ មិនសម្លាប់គេ មិនលួចគេជាដើម. បើកាលណាទៅសាលារៀន ទៅឱ្យទាន់ម៉ោង មិនប្រឡែងគ្នាលេងក្នុងពេលដែលមិនត្រូវលេង ខំប្រឹងរៀនមេទន្ទេញឱ្យចាំ. យ៉ាងនេះហៅថាធ្វើអំពើល្អ. ការធ្វើអំពើល្អនេះ ត្រូវបានល្អវិញ គឺត្រូវគេខ្លាចចិត្ត គេអាណិតមកកុញ្ញរឯងវិញ គេមិនវាយកុញ្ញរឯងវិញ គេឱ្យសុខមកវិញ ពុំនោះត្រូវបានទទួលសេចក្ដីអាណិតអាសូរអំពីម្ដាយឪពុកឯងកាន់តែខ្លាំងឡើងៗ ឬបានសេចក្ដីសរសើរពីគ្រូបង្រៀនក្នុងសាលាពុំខាន ។ ហេតុនេះបានជាព្រះពុទ្ធជាម្ចាស់ត្រាស់ប្រដៅថា ឱ្យធ្វើតែអំពើល្អជាដរាប ។ ម៉េចឯងស្ដាប់បានទេ ?

**កុ.** ទានព្រោស ស្ដាប់បានហើយដូចជាងាយយល់សោះទេតើ។ ទានចុះត្រង់ខទី៣ថាឱ្យជុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតនោះ តើត្រូវធ្វើដូចម្ដេចទៅ?

**ឌ.** ឱកុញ្ញរ. ត្រង់ខទី៣ នេះនិយាយពីការជុសខាត់ចិត្ត ជំរះចិត្តឱ្យស្អាត. អាត្មាពិបាកនឹងពន្យល់ឯងឱ្យស្ដាប់បានណាស់ ព្រោះចិត្តឥតមានរូបរាងទេ មើលមិនឃើញ ចាប់កាន់ដោយដៃមិនបាន ពាក្យបាលីហៅថា អរូបធម៌ ឬនាមធម៌ គឺឥតរូបមានតែឈ្មោះប៉ុណ្ណោះ. ខ្លួនឯងនៅក្មេងស្ដាប់ រឿងចិត្តមិនងាយយល់ទេ

Websites: WatKhemaraRatanaram.org or WatKhmers.org



ប៉ុន្តែណ្ហើយចុះ អាត្មាសួរឯងបន្តិច, ឯងធ្លាប់ដែលស្រឡាញ់របស់អ្វីៗ ហើយទារពីឪពុកម្ដាយឯងឱ្យរកឱ្យដែរឬទេ? ឯងដែលខឹងនឹងគេដែលគេវាយឯង គេជេរឯងដែរឬទេ?

ក្មុ. ទានព្រេស, ធ្លាប់មានរឿយៗណាស់ ស្រឡាញ់របស់នេះ របស់នោះ ហើយទារពីឪពុកម្ដាយខ្ញុំព្រះករុណាឱ្យរកឱ្យតែមិនបាន ខ្ញុំព្រះករុណាមិនសប្បាយចិត្តទេ, ខឹងសម្បាក៏ធ្លាប់មាន ស្អប់គេក៏ធ្លាប់មាន ។

ឥះ. អើ កុល្បរ, ខឹងក្ដី ស្រឡាញ់ក្ដី ស្អប់ក្ដី ឯងដឹងទេ អ្វីដែលចេះស្រឡាញ់ ចេះស្អប់ ចេះខឹង ?

ក្មុ. ទានព្រេស, គឺខ្ញុំព្រះករុណានេះហើយដែលចេះស្រឡាញ់ ចេះស្អប់ ចេះខឹង ។

ឥះ. អើឯងថាខ្លួនឯងត្រូវហើយ ប៉ុន្តែដៃជើង ឬមាត់ ឬក៏ខ្លួនឯង ត្រង់ណាឯងចង្អុលប្រាប់អាត្មាមកមើលដែលចេះស្រឡាញ់ចេះស្អប់ ចេះខឹង។

ក្មុ. ទានព្រេស, ព្រះគុណម្ចាស់សួរដូច្នេះខ្ញុំព្រះករុណាមិនដឹងឆ្លើយទេ។

ឥះ. អើ កុល្បរ, ហ្នឹងហើយតើដែលអាត្មាថា ឯងនៅក្មេងពិបាកយល់ណាស់ ហ្នឹងហើយណា: ដែលគេហៅថាចិត្តៗនៅក្នុងរូបកាយយើង ចេះស្រឡាញ់ ចេះស្អប់ ចេះខឹង ចេះប្រកាន់, ចិត្តនេះកាលណាស្រឡាញ់អ្វីៗ ក្ដី ស្អប់អ្វីៗក្ដី ខឹងនឹងគេក្ដី គេហៅថាចិត្តសៅហ្មង ចិត្តប្រឡាក់ ចិត្តមិនស្អាត ចិត្តដូច្នេះ ពេញាះថាចិត្តមិនបរិសុទ្ធ មិនល្អ, ចិត្តមិនបរិសុទ្ធមិនល្អនេះហើយ ដែល

Websites: WatKhemaraRatanaram.org or WatKhmers.org



នាំមនុស្សឱ្យធ្វើអាក្រក់, អំពើអាក្រក់នាំអ្នកធ្វើឱ្យបានទុក្ខទោស បានជាព្រះពុទ្ធជាម្ចាស់ប្រដៅថា ត្រូវធ្វើចិត្តរបស់ខ្លួនឱ្យស្អាត ឱ្យល្អទៅ ព្រោះចិត្តស្អាត ចិត្តល្អនាំមនុស្សឱ្យធ្វើអំពើល្អ, អំពើល្អនាំអ្នកធ្វើឱ្យបាននូវសេចក្ដីសុខស្រួល, ម៉េចឯងស្ដាប់បានទេ ?

ក្មុ. ទានព្រោស ស្ដាប់បានហើយ, ប៉ុន្តែការជំរះជុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតនោះ ត្រូវធ្វើដូចម្ដេច ?

ឌ. អាត្មាពិបាកពន្យល់ណាស់ ព្រោះកិច្ចនេះជ្រាលជ្រៅពេក ប៉ុន្តែណើ្អយចុះ កុញ្ញរឯងចាំដល់ធំឡើងសឹមសិក្សារៀនឱ្យស្គាល់វិធីជំរះចិត្ត ដោយពិស្ដារ ឥឡូវនេះកុំអាលគិតសិនចុះ អាត្មាគ្រាន់តែប្រាប់ឯងឱ្យដឹងយ៉ាងរាក់ៗ បើកាលណាឯងស្រឡាញ់អ្វីខ្លាំង ឯងខឹងខ្លាំង ត្រូវដឹងខ្លួនថា ឱចិត្ត របស់អញមិនល្អហើយតើ ! ត្រូវឈប់ស្រឡាញ់ ត្រូវឈប់ខឹង, បើឯងខ្ជិល ត្រូវតាំងចិត្តឱ្យរឹងប៉ឹងខំរៀនទន្ទេញឱ្យម៉ឺងម៉ាត់, បើធ្វើបានត្រឹមប៉ុណ្ណេះក៏ឈ្មោះថាបានជុសខាត់ជំរះចិត្តឱ្យស្អាតបានយ៉ាងមធ្យមដែរ ។ ម៉េចឯងស្ដាប់ យល់ទេ ?

ក្មុ. ទានព្រោស, ប៉ុណ្ណឹងក៏ល្មមស្ដាប់យល់បានហើយ, ខ្ញុំព្រះករុណាពេញចិត្តណាស់ ។ ទានព្រោស ព្រះពុទ្ធសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមានតែប៉ុណ្ណេះទេ ឬក៏នៅមានច្រើនទៅទៀត ?

ឌ. យី កុញ្ញរ អាត្មាបានប្រាប់ពីខាងដើមមកហើយតើ ឯងភ្លេចទេដឹង? ព្រះពុទ្ធសាសនាមានច្រើនណាស់, ព្រះពុទ្ធបានត្រាស់ឡើងសំដែងធម៌ប្រដៅ

Websites: WatKhemaraRatanaram.org or WatKhmers.org



សត្វលោកអស់៤៥ឆ្នាំ ធម៌ដែលព្រះអង្គសំដែងទាំងប៉ុន្មាន ហៅថា ព្រះពុទ្ធសាសនាទាំងអស់ ។ ព្រះធម៌ទាំងនោះ អ្នកណាអាចប្រតិបត្តិធ្វើតាម អ្នកនោះនឹងបានសេចក្តីសុខចំរើន តាំងពីក្នុងបច្ចុប្បន្នកាលនេះទៅដល់អនាគត នឹងបានដល់នូវព្រះនិព្វានទៀត ។ ក្នុងថ្ងៃនេះ អាត្មាពន្យល់ចំពោះតែគោលព្រះពុទ្ធសាសនាទាំងបីយ៉ាង ដូចឯងបានដឹងរួចហើយ ប៉ុន្តែអាត្មាចង់ឱ្យឯងទន្ទេញឱ្យចាំ តាមពាក្យកាព្យជាបទកាកគតិ ដែលរួបរួមគោលព្រះពុទ្ធសាសនាទាំងបីនោះ ដូចខាងក្រោមនេះ :

ព្រះពុទ្ធបានត្រាស់ ប្រាកដជាក់ច្បាស់ ប្រៀនសត្វនិករ ពាក្យប្រៀនប្រដៅ នោះហៅព្រះធម៌ ធម៌នោះបវរ ហៅពុទ្ធសាសនា ។ ព្រះសាសនានោះ ព្រះអង្គសង្គ្រោះ រួមជាមាត្រាមានត្រឹមបីយ៉ាង ជាឱវាទា ឱ្យសត្វនានាចងចាំបានងាយ ។ មួយគឺកុំឱ្យ សព្វសត្វធ្វេសធ្លោយធ្វើបាប សម្មាយមួយគឺឱ្យធ្វើបុណ្យផងទាំងឡាយ មួយកុំពាយងាយធ្វើចិត្តឱ្យស្អាត។ គឺឱ្យជំរះចិត្តឱ្យស្រឡះ កុំឱ្យគ្រោតគ្រាត កុំឱ្យសៅហ្មង ដោយការប្រមាទ នេះជាឱវាទនៃព្រះពុទ្ធា ។ បិដកទាំងបី ព្រះសូត្រវិន័យបរមត្ថធម្មា ពោលដោយសង្ខេប មានត្រឹមបីឃ្លា ដូចបានពណ្ណនា ខាងលើនេះហោង ។

ក្មុ. សេចក្តីរួបរួមគោលព្រះពុទ្ធសាសនាទាំងបី ជាបទកាព្យនេះ ខ្ញុំព្រះករុណាទាំងអស់គ្នាពេញចិត្តណាស់ នឹងទន្ទេញឱ្យចាំដើម្បីកុំឱ្យភ្លេចគោលព្រះពុទ្ធសាសនា ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ឆ. ណ្ហើយ កុញ្ញរ. ប៉ុណ្ណឹងល្មមហើយ ឯងទាំងអស់គ្នាដល់ពេលល្មមទៅផ្ទះហើយទៅចុះ. ប៉ុន្តែមុននឹងទៅឯងទាំអស់គ្នាត្រូវកត់ពាក្យនមស្ការថ្វាយបង្គំព្រះធម៌យកទៅទន្ទេញឱ្យចាំ អាត្មាធ្វើជាពាក្យកាព្យបទព្រហ្មគីតិ ដូចខាងក្រោមនេះ :

យើងខ្ញុំសូមបង្គំ ធម៌ឧត្តមប្រកបអង្គ
ប្រាំបីជាផ្លូវត្រង់ របស់អង្គព្រះអរិយា ។
នាំសត្វចូលនិព្វាន ទីដែលគ្មានក្តីទុក្ខា
ជាធម៌ដ៏ថ្លៃថ្លា ធ្វើក្តីសុខស្ងប់សព្វកាល ។
យើងខ្ញុំសូមព្រះធម៌ គុណបវរជួយសម្រាល
ទុក្ខភ័យឱ្យបានស្រាល ពីឥឡូវនេះទៅហោង ។

ក្មេ. ទានព្រោស. ខ្ញុំព្រះករុណានិងមិត្រភ័ក្តិរបស់ខ្ញុំព្រះករុណា បានចម្លងរួចហើយ នឹងយកទៅទន្ទេញឱ្យចាំ ដល់ថ្ងៃស្អែកនឹងមកកាន់សំណាក់ព្រះគុណម្ចាស់ ដើម្បីនឹងសិក្សាតទៅទៀត ។

ឆ. អើទៅចុះ! សុខិតា ហោថ! សូមឱ្យសុខសប្បាយទាំងអស់គ្នា ណា:!

ក្មេងទាំអស់គ្នាទទូលថា: ព្រះករុណា! សាធុ! សាធុ!

Websites: WatKhemaraRatanaram.org or WatKhmers.org

Websites: WatKhemaraRatanaram.org or WatKhmers.org

# ព្រះសង្ឃ

ដល់ពេលបង្រៀនរឿង ព្រះពុទ្ធសាសនា លោកធម្មធរៈ បានផ្ដើមនិយាយនឹងពួកក្មេងៗជាសិស្សថា :

ពីម្សិលមិញ អាត្មាបានបង្រៀនរឿងព្រះពុទ្ធសាសនាយ៉ាងសង្ខេប ម៉េចឯងរាល់គ្នាចាំបានហើយឬ? ក្មេងទាំងអស់ឆ្លើយថា ទានប្រោសចាំហើយ។លោកធម្មធរៈ និយាយតទៅទៀតថា អាត្មាបង្រៀនដូច្នេះ ដោយឃើញឯងទាំងអស់គ្នានៅក្មេងណាស់ បើបានយល់ត្រឹមប៉ុណ្ណេះក៏សមគួរដល់ជាតិរបស់ខ្លួនយើងដែលជាអ្នកកាន់ពុទ្ធសាសនាដែរហើយ កាលណាឯងរាល់គ្នាចំរើនវ័យធំខ្លួនឡើង សឹមសិក្សាតទៅទៀត ។ លោកធម្មធរៈផ្ដើមនិយាយ ប៉ុណ្ណេះហើយ ក៏ក្រោកឡើងទៅសរសេរអក្សរធំៗនៅលើក្ដារខៀបញ្ឍរថា ព្រះសង្ឃ ហើយហៅក្មេង១នាក់ផ្សេងឈ្មោះឧទ័យឱ្យមកមើល។ ឧទ័យ ក្រោកឡើងដើរទៅជិតក្ដារសរសេរអានថា ព្រះសង្ឃ ។

ធម្មធរៈ_ អើឯងអានហ្នឹងត្រូវហើយ ប៉ុន្តែឯងត្រូវចាំណា:គេសរសេរអក្សរ ស ប្រកបនឹងតួរ ង៉ តម្រួតជើង ឃ តែមិនដាក់ជើងអក្សរ ឃ មិនត្រូវទេ ព្រោះពាក្យនេះជាបាលី ។

ឧ. ទានប្រោស ចាំបានហើយ ប៉ុន្តែខ្ញុំព្រះករុណាឆ្ងល់. ហេតុដូចម្ដេចក៏ចាំយកពាក្យបាលីមកប្រើ? ចុះបើយើងប្រើតែពាក្យខ្មែរសុទ្ធមិនបានឬ ?

ធ. មិនបានទេ ឧទ័យ. ព្រោះភាសាខ្មែរយើងលាយដោយភាសាបាលី.

Websites: WatKhemaraRatanaram.org or WatKhmers.org



ភាសាសំស្រ្កឹតប្រហែល៣០ភាគរយ ប៉ុន្តែភាសាបាលី នឹងសំស្រ្កឹតទាំងនោះ ជាតិខ្មែរយើងទោះបីមិនចេះក៏គង់អាចនិយាយបាន ស្តាប់បានគ្រាន់តែមិនបានជ្រាលជ្រៅប៉ុណ្ណោះ ទាំងសរសេរក៏មិនសូវត្រឹមត្រូវ តែបើអ្នកណាគេយកចិត្តទុកដាក់ អ្នកនោះអាចនិយាយ, អាចសរសេរ ព្រមទាំងដឹងសេចក្តីដោយជ្រាលជ្រៅបាន។ ប្រសិនបើគិតរើសយកបាលី នឹងសំស្រ្កឹតចេញឱ្យអស់ ទុកឱ្យនៅសល់តែភាសាខ្មែរសុទ្ធ នោះខ្មែរលែងនិយាយការអ្វីកើតហើយ ។ ឧទ័យឯងត្រូវដឹង ប្រទេសទាំងអស់ក្នុងលោក គេមិនដែលបង្រួញភាសាឱ្យខ្លី ឱ្យតិចចុះទេ គឺគេមានគណៈកម្មការបង្កើតភាសាបន្ថែម ឱ្យមានកាន់តែច្រើនឡើងៗ តាមចំនួនមនុស្សនឹងរបស់ប្រើប្រាស់ ដែលកាន់តែមានច្រើនៗ ប្លែកៗឡើង ។ ប្រទេសយើងក៏ដូចជាប្រទេសគេឯទៀតៗដែរ កាលណាភាសាយើងយកទៅប្រើមិនគ្រប់សព្វ ត្រូវតែបង្កើតពាក្យថ្មី ដោយជ្រើសរើសយកភាសាបាលីខ្លះ សំស្រ្កឹតខ្លះមកផ្សំ ដើម្បីឱ្យសម្បូរភាសាឡើង, សម័យសព្វថ្ងៃនេះ ក៏កំពុងតែមានការបង្កើតភាសាបន្ថែមជានិច្ច ។ ហេតុនេះ យើងដែលជាកូនខ្មែរ គួរតែខំប្រឹងរៀនឱ្យបានចេះដឹងភាសាសម្រាប់ជាតិ ទោះបីភាសានោះក្លាយមកពីភាសាអ្វី ក៏ត្រូវឱ្យដឹង មិនត្រូវធុញទ្រាន់ទិភាសារបស់ខ្លួន ដោយសេចក្តីខ្ជិលច្រអូសទេ ព្រោះភាសាក្នុងលោកសព្វថ្ងៃ កាន់តែចំរើនឡើងៗ ហើយរាយផ្សាយពីប្រទេសមួយទៅប្រទេសមួយ បើយើងមិនខំប្រឹង ហើយយើងយកការខ្ជិលច្រអូសមកដាក់ពីមុខ យើងនឹងធ្លាក់ទៅក្នុងរណ្តៅនៃសេចក្តីងងឹតល្ងង់ នាំឱ្យអាប់ឱនយ៉ាងធំសម្បើមទៅក្នុងអនាគត

Websites: WatKhemaraRatanaram.org or WatKhmers.org



កុំខាន ។

ហេតុនេះ, ឧទ័យឯងត្រូវតាំងចិត្តខ្លួនឯង ព្រមទាំងបបួលមិត្រភ័ក្តិទាំងអស់គ្នា ឱ្យតាំងចិត្តគិតរៀនឱ្យចេះភាសារបស់ខ្លួនយ៉ាងច្បាស់លាស់ ដើម្បីឱ្យដឹងថា ពាក្យនេះជាពាក្យខ្មែរសុទ្ធ ឬជាពាក្យបាលី, សំស្រ្កឹត ឬក៏ជាពាក្យក្លាយមកពីពាក្យរបស់ជាតិណា ត្រូវសរសេរដូចម្តេចទើបត្រឹមត្រូវ? កុំធុញទ្រាន់ កុំខ្ជិលក្នុងការរៀនសូត្រឡើយ ។

ឱ. ករុណា, ខ្ញុំព្រះករុណាមិនធុញទ្រាន់ទេ ប៉ុន្តែឮគេនិយាយថា អស់លោកអ្នកចេះភាសាបាលីសំស្រ្កឹត គិតយកតែបាលីសំស្រ្កឹតមកប្រើ ឱ្យតែលំបាកស្តាប់តាំងពីយូរណាស់មកហើយ, ខ្ញុំព្រះករុណាមិនដឹងជាភាសាខ្មែរយើង លាយដោយភាសាបាលីសំស្រ្កឹតដូច្នេះសោះ ឥឡូវនេះដឹងហើយ យល់ហើយ, តាំងពីថ្ងៃនេះទៅ ខ្ញុំព្រះករុណានឹងខំប្រឹងរៀនឱ្យចេះដឹង ។

ឥ. អើ បើឯងយល់ហើយ អាត្មាអរណាស់, ឥឡូវនេះអាត្មានឹងសួរឯងតទៅទៀត, ព្រះពុទ្ធសាសនាឯងបានរៀនពីថ្ងៃមុនរួចទៅហើយ ។ ឯងដឹងទេ អ្នកណាជាអ្នករក្សាព្រះពុទ្ធសាសនា ឱ្យបានឋិតថេរយូរអង្វែងអស់២៥៣៤ ឆ្នាំមកនេះ ?

ឱ. ទានប្រោស ខ្ញុំព្រះករុណាមិនដឹងទេ ។

ឥ. អីឯងមិនដឹងទេ, ព្រះសង្ឃណា:! លោកជាអ្នកថែរក្សាព្រះពុទ្ធសាសនាឱ្យឋិតថេរតមក, មិនមែនត្រឹមតែរក្សាប៉ុណ្ណោះទេ ព្រះសង្ឃមានភារៈ

Websites: WatKhemaraRatanaram.org or WatKhmers.org



ក្នុងការប្រព្រឹត្តិកាន់ផ្ទាល់ខ្លួន តាមព្រះពុទ្ធសាសនាផង ជួយដឹកនាំជនទាំងឡាយឱ្យជឿកាន់តាមព្រះពុទ្ធសាសនាផង ។

ខ. ទានប្រោស, បើដូច្នោះ ព្រះសង្ឃលោកមានការរវល់ច្រើនណាស់ក្នុងរឿងព្រះពុទ្ធសាសនា ។

ឍ. ព្រះសង្ឃលោកមានការរវល់ច្រើនណាស់ ក្នុងរឿងព្រះពុទ្ធសាសនា ព្រោះកាលព្រះពុទ្ធគង់នៅឡើយ ព្រះអង្គបានប្រគល់កិច្ចការរបស់ព្រះអង្គ ឱ្យពួកសង្ឃសម្រេច ទ្រង់ទុកពួកសង្ឃជាធំក្នុងកិច្ចការគ្រប់យ៉ាង ទាំងព្រះអង្គឯងក៏រាប់ចូលក្នុងពួកសង្ឃដែរ ។ លុះឥតពីព្រះពុទ្ធទៅ នៅមានតែព្រះសង្ឃជាអ្នកតំណាងព្រះពុទ្ធ តំណាងព្រះពុទ្ធសាសនាគឺ **ព្រះធម៌** ធ្វើកិច្ចការគ្រប់យ៉ាងក្នុងព្រះពុទ្ធសាសនា ។

ខ. ទានប្រោស, បើដូច្នោះព្រះសង្ឃមានយូរហើយ កាលព្រះពុទ្ធគង់នៅម្ល៉េះ ។

ឍ. ឱ ឧទ័យមិនដឹងទេតើ, កាលព្រះពុទ្ធគង់នៅ ព្រះសង្ឃថ្នាក់ខ្ពស់ដែលហៅថា **អរិយសង្ឃ**ក៏មាន,ព្រះសង្ឃជាបុថុជ្ជន ដែលហៅថា **សម្មតិសង្ឃ** ដូចសង្ឃក្នុងសម័យឥឡូវនេះក៏មាន។ នែឧទ័យ, រឿងព្រះសង្ឃនោះមានកិច្ចត្រូវនិយាយច្រើនណាស់ ព្រោះព្រះសង្ឃនោះមានគុណសម្បត្តិ គួរជនទាំងឡាយគោរពបូជាជានិច្ចដូចជា **ព្រះពុទ្ធ** នឹង**ព្រះធម៌**ដែរ ប៉ុន្តែក្នុងពេលនេះអាត្មាមិនចង់និយាយពន្យល់ឯងទេ ព្រោះឯងនៅក្មេងណាស់ កុំអាលស្តាប់ កុំ

Websites: WatKhemaraRatanaram.org or WatKhmers.org



អាលរៀនរឿងព្រះសង្ឃឱ្យពិស្តារពេកចុះ ត្រូវរៀនឱ្យដឹងតែរឿងព្រះសង្ឃក្នុងកាលឥឡូវនេះ ដែលល្មមសង្កេតទៅឃើញនឹងភ្នែកយ៉ាងជាក់ច្បាស់ជាមុនសិន លុះដល់ឯងធំឡើង ចាំសិក្សាតទៅទៀត ។

ខ. ករុណា, បើដូច្នោះ សូមព្រះគុណម្ចាស់មេត្តាពន្យល់យ៉ាងណា ឱ្យខ្ញុំព្រះករុណាបានយល់ អំពីរឿងព្រះសង្ឃក្នុងបច្ចុប្បន្ននេះឱ្យទាន ។

ឌ. ឧទ័យ, ព្រះសង្ឃសព្វថ្ងៃនេះ ជាប់ពូជតអំពីព្រះសង្ឃជាន់មុនៗ មកដែរ ។ ព្រះសង្ឃលោកអាស្រ័យនៅក្នុងវត្តអារាម លោកធ្វើកិច្ចការផ្សេងអំពីគ្រហស្ថ គឺលោកធ្វើការងារចំពោះទៅលើផ្លូវព្រះពុទ្ធសាសនា ឬផ្លូវធម៌ ។ ត្រង់កិច្ចការរបស់គ្រហស្ថ ដូចជាធ្វើស្រែចំការ, ធ្វើជំនួញជាដើម ព្រះសង្ឃលោកមិនធ្វើទេ ។

ខ. ទានព្រោស, ព្រះសង្ឃបើលោកមិនធ្វើស្រែចំការជាដើមទេ ហេតុម្តេចក៏លោកបានអាហារភោជនឆាន់ចិញ្ចឹមជីវិតរាល់ថ្ងៃ? ទាំងទីកន្លែងវត្តអារាមដែលលោកអាស្រ័យនៅ ហេតុដូចម្តេចក៏ចេះតែមាន ?

ឌ. យី ឧទ័យឯងមិនដឹងទេឬ? សព្វថ្ងៃនេះ ពួកព្រះសង្ឃលោកដើរសូមគេ គឺដើរបិណ្ឌបាតចង្ហាន់ ជូនកាលពួកគ្រហស្ថគេយកមកប្រគេនលោកដល់វត្តក៏មាន ទាំងទីវត្តអារាមមានកុដិសាលាវិហារជាដើម ក៏ពួកគ្រហស្ថគេរៃប្រាក់គ្នាយកទៅកសាងប្រគេនឱ្យលោកនៅដែរ មិនតែប៉ុណ្ណោះឡើយ គ្រហស្ថតែងគោរពនមស្ការ បូជាចំពោះព្រះសង្ឃទាំងនោះផងទៀត ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ខ្ញ. ទានប្រោស, បើដូច្នោះព្រះសង្ឃដូចជាស្រួលណាស់ ឥតធ្វើការងាររកបរអ្វីសោះ មានគេឱ្យស្រាប់ៗទាំងទីលំនៅក៏គេធ្វើឱ្យស្រាប់ៗដែរ ហើយថែមទាំងមានគេគោរពបូជាផងទៀត, ខ្ញុំព្រះករុណានឹកទៅគួរឱ្យឆ្ងល់ណាស់ ហេតុម្ដេចក៏ពួកគ្រហស្ថនាំគ្នាលើកដំកើងព្រះសង្ឃឱ្យនៅជាសុខស្រួលអីម្លេះ?

ឌ. ឱ ឧទ័យ, ព្រះសង្ឃដែលមិនធ្វើការងារដូចគ្រហស្ថ ហើយមាន ពួកគ្រហស្ថគេជួយឱ្យចង្ហាន់ គេគោរពយ៉ាងនេះ មិនមែនព្រះសង្ឃទាំងនោះ នៅទំនេរស្រួលទេ គឺព្រះសង្ឃទាំងនោះមានការងារច្រើនណាស់ ប៉ុន្តែជាការងារផ្សេងពីគ្រហស្ថ ។ ឧទ័យឯង ចាំស្ដាប់អាត្មានិយាយឱ្យស្ដាប់ពីការងាររបស់ព្រះសង្ឃដូចខាងក្រោមនេះ :

១- វត្តអារាមដែលគ្រហស្ថគេធ្វើរួចហើយ ព្រះសង្ឃនៅថែរក្សាវត្តអារាមនោះឱ្យស្អាតបាតសមរម្យ ជាទីដំកល់ព្រះពុទ្ធសាសនាព្រមទាំងជួយចាត់ចែងកិច្ចការគ្រប់យ៉ាងក្នុងវត្តអារាម ដែលទាក់ទងដល់ផ្លូវព្រះពុទ្ធសាសនា,

២- ព្រះសង្ឃខំរៀនសូត្រធម៌វិន័យជាច្បាប់ ខាងព្រះពុទ្ធសាសនាឱ្យបានចេះដឹង លុះចេះដឹងហើយ ខំប្រតិបត្តិកាន់តាមច្បាប់ព្រះពុទ្ធសាសនាឱ្យបានត្រឹមត្រូវចំពោះខ្លួនឯង ,

៣- ខំពន្យល់ពួកគ្រហស្ថឱ្យចេះដឹងច្បាប់ព្រះពុទ្ធសាសនា ហើយដឹកនាំគេឱ្យចូលកាន់ព្រះពុទ្ធសាសនាផងទៀត ដោយវិធីទេសនាពន្យល់ខ្លះ ដោយវិធី

Websites: WatKhemaraRatanaram.org or WatKhmers.org



បង្ហាត់បង្រៀនខ្លះ ។ល។

កិច្ចទី៣នេះ ឈ្មោះថាព្រះសង្ឃបានដឹកនាំប្រជាជន ឱ្យមានសណ្ដាប់ធ្នាប់ល្អ មានសីលធម៌ប្រពៃ សមជាពលរដ្ឋក្នុងប្រទេសប្រាកដដូចជា ព្រះសង្ឃបានជួយដល់រដ្ឋាភិបាលមួយចំណែកក្នុងការណែនាំប្រជារាស្ត្រឱ្យមានសីលធម៌ ។

ម្យ៉ាងទៀត, ឧទ័យឯងនៅក្មេងមិនសូវដឹងទេ តាំងពីបុរាណកាលមក វត្តអារាមនីមួយៗ ក្នុងប្រទេសយើងនេះ ទុកដូចជាសាលារៀនសម្រាប់ពួកយុវជន ត្រកូលណាដែលមានកូនប្រុសតាំងពីអាយុ៧-៨ឆ្នាំឡើងទៅ, គេយកកូនទាំងនោះ ឱ្យទៅរៀនអក្សរសាស្ត្រខ្មែរឯវត្ត, លោកគ្រូចៅអធិការវត្ត បានចាត់ឱ្យព្រះសង្ឃក្នុងវត្តបង្រៀនអក្សរឱ្យចេះដឹង ព្រមទាំងបង្ហាត់បង្រៀនធម៌អាថ៌ព្រះពុទ្ធសាសនាទៀតផង ដរាបទាល់តែក្មេងទាំងនោះ បានចេះដឹងអក្សរសាស្ត្រសម្រាប់ជាតិ ឥតមានទាយកតម្លៃឈ្នួលអ្វីពីឪពុកម្ដាយក្មេងទាំងនោះទេ ហេតុនោះលោកសង្ឃក្នុងវត្ត ទុកជាគ្រូបង្រៀនកូនអ្នកស្រុកយ៉ាងថ្លៃថ្នូរ. កិច្ចដែលព្រះសង្ឃជួយធុរៈក្នុងការបង្ហាត់បង្រៀននេះ ឈ្មោះថាព្រះសង្ឃ ជួយដល់រដ្ឋាភិបាល ជួយឱ្យបានចម្រុងចម្រើនដល់ប្រទេសមួយចំណែក ។ លុះតមករាជការក្នុងប្រទេសយល់ឃើញថា ពួកពលរដ្ឋពេញចិត្តនឹងវត្តអារាមណាស់ ពេញចិត្តនឹងយកកូនចៅឱ្យទៅនៅសិក្សាក្នុងវត្តអារាមក៏បាន ចាត់ចែងឱ្យមានសាលារៀនក្នុងវត្ត ចាត់គ្រូឱ្យទៅបង្រៀនដើម្បីឱ្យក្មេងៗបាន ចម្រើនចំណេះវិជ្ជាខ្ពស់ឡើងទៀត គ្រូទាំងនោះជាភារៈលើរាជការចិញ្ចឹម ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ចំណែកព្រះសង្ឃក្នុងវត្ត ទោះបីផុតពីកិច្ចបង្ហាត់បង្រៀនអក្សរសាស្ត្រខ្លួនឯងខ្លះហើយក៏ដោយ គង់តែនៅមានការទទួលភារៈជួយកសាងសាលារៀន, ជួយចិញ្ចឹមក្មេងៗដែលម្ដាយឪពុកទ័លក្រ ឬដែលនៅឆ្ងាយៗយកមកផ្ញើទុកនៅវត្ត, ជួយរំលឹកដាស់តឿនប្រដៅក្មេងៗឱ្យខំសិក្សារៀនសូត្រជានិច្ច, កិច្ចនេះក៏ឈ្មោះថាព្រះសង្ឃបានរំលែកកម្លាំងពីកិច្ចការខាងព្រះពុទ្ធសាសនា ទៅជួយដល់រាជការផែនដីនាំឱ្យរដ្ឋាភិបាលបានធូរចិត្តគំនិតមួយចំណែកដោយសារព្រះសង្ឃ។

នៅទីក្រុងសព្វថ្ងៃនេះ ក្នុងទីវត្តអារាមផ្សេងៗ មានវត្តឧណ្ណាលោមជាដើម សុទ្ធតែមានពួកក្មេងៗនៅគ្រប់តំបន់ក្នុងព្រះរាជអាណាចក្រ ម្ដាយឪពុកបានយកមកផ្ញើទុកឱ្យនៅរៀនសូត្រជាចំនួនច្រើន, ក្មេងទាំងនោះសុទ្ធតែព្រះសង្ឃជួយចិញ្ចឹម ជួយឱ្យកន្លែងអាស្រ័យនៅដោយឥតមានចេញថ្លៃ ហើយបានចូលរៀនក្នុងសាលារាជការរហូតដល់បានចេះដឹង ហើយចេញទៅធ្វើការរាជការក៏មានចំនួនច្រើនណាស់តាំពីយូរមកហើយ ។ សព្វថ្ងៃនេះ ក៏នៅតែមានក្មេងៗមកអាស្រ័យនៅតាមវត្តអារាមក្នុងមួយវត្តៗមានចំនួន១០០ នាក់ក៏មាន២០០នាក់ក៏មាន ច្រើនជាងនេះក៏មាន សុទ្ធតែព្រះសង្ឃក្នុងវត្ត លោកជួយគ្រប់គ្រងរក្សាឱ្យបានសុខស្រួលដោយអាហារ នឹងទីលំនៅ, កិច្ចនេះក៏ឈ្មោះថា ព្រះសង្ឃជួយសង្គ្រោះដល់ប្រជាជនទ័លក្រ, ជួយដល់រដ្ឋាភិបាល ជួយដល់ប្រទេស ។

ខ. ព្រះគុណម្ចាស់ ពន្យល់ពីវត្តអារាម នឹងព្រះសង្ឃនៅទីក្រុងភ្នំពេញឃើញថាមានប្រយោជន៍ណាស់, ទានប្រោស ចុះវត្តអារាមនៅខេត្តក្រៅដូច

Websites: WatKhemaraRatanaram.org or WatKhmers.org



ម្តេចទៅ ?

ឌ. ឧទ័យ. នៅខេត្តក្រៅក៏ដូចជានៅទីក្រុងភ្នំពេញដែរ ប្លែកគ្នាតែត្រង់មានចំនួនក្មេងតិចនឹងច្រើនប៉ុណ្ណោះ ព្រោះប្រជាជនខ្មែរពេញចិត្តនឹងវត្តអារាមណាស់ មិនមែនត្រឹមតែទុកវត្តអារាមជាកន្លែងសម្រាប់ឱ្យកូនចៅនៅរៀនសូត្រ សម្រាប់ធ្វើបុណ្យទានយកផលប៉ុណ្ណោះឡើយ ថែមទាំងទុកវត្តអារាមជាកន្លែងសម្រាប់បន្ទោរបង់នូវទុក្ខព្រួយផងទៀត ទុកវត្តអារាមជាសួនច្បារឧទ្យានរបស់ខ្លួនសម្រាប់ចូលទៅលំហែនាំឱ្យធូរចិត្តគំនិត១ចំណែកបាន ។ ហេតុនេះ បានជាប្រជាជនខ្មែរនាំគ្នាទៅនៅធ្វើជាភូមិភាគ ក្នុងទីណាដែលឥតមានវត្តអារាមនៅជិតក៏តាំងផ្តើមនាំគ្នាសូមអនុញ្ញាតកសាងវត្តឱ្យមានឡើង ។

ខ្ញុំឃើញ ព្រះសង្ឃដែលនៅក្នុងវត្តអារាម ក្នុងព្រះពុទ្ធសាសនា លោកបំពេញកិច្ចការក្នុងព្រះពុទ្ធសាសនាផង លោកជួយឧបត្ថម្ភប្រជាជន ជាពលរដ្ឋក្នុងប្រទេសផង ជួយឱ្យរដ្ឋាភិបាលបានធូរស្រាលមួយចំណែកផង ។

អាស្រ័យហេតុដូចមានខាងលើនេះ ទើបប្រជាជនក្នុងប្រទេស ត្រឡប់ជួយដល់ព្រះសង្ឃវិញ ដោយប្រគេនអាហារភោជន. ដោយធ្វើវត្តអារាមឱ្យគង់នៅ ព្រមទាំងមានចិត្តភក្តីគោរពបូជាដល់ព្រះសង្ឃផងទៀត ដោយយល់ឃើញថា ពួកព្រះសង្ឃលោកធ្វើការនាំឱ្យមានផលប្រយោជន៍ សំខាន់ណាស់ដល់ព្រះពុទ្ធសាសនាផង ដល់ប្រទេសជាតិផង មិនមែនឥតប្រយោជន៍ឡើយ ។ ម៉េចឯងយល់ទេ. ស្តាប់បានទេ ?

Websites: WatKhemaraRatanaram.org or WatKhmers.org



ខ្ញុំ. ទានប្រោស, យល់ហើយ ស្តាប់បានហើយ. បើតាមព្រះថេរដីកាដែលរៀបរាប់មកនេះ ឃើញថាព្រះសង្ឃមានកិច្ចការច្រើនណាស់ ហើយកិច្ចការរបស់ព្រះសង្ឃ សុទ្ធតែជាការមានប្រយោជន៍ ប៉ុន្តែខ្ញុំព្រះករុណាឆ្ងល់ណាស់ ហេតុដូចម្តេចបានជាមានមនុស្សខ្លះពុំដឹង ហើយចេះតែនិយាយថា ព្រះសង្ឃពុំមានកិច្ចការអ្វីដែលនាំឱ្យមានផលប្រយោជន៍សោះឡើយ ?

ឧ. ឧទ័យឯងកុំឆ្ងល់អ្វី, ព្រោះមនុស្សណាពុំដែលចូលទៅក្នុងវត្តអារាម ពុំដែលមានការប្រាស្រ័យជាមួយនឹងព្រះសង្ឃ ពុំដែលបានសិក្សា រៀនព្រះពុទ្ធសាសនាសោះ មនុស្សនោះពុំអាចដឹងកិច្ចការរបស់សង្ឃឡើយ ព្រមទាំងមិនដឹងច្បាប់ព្រះពុទ្ធសាសនាផងទៀត ។

ខ្ញុំ. ទានប្រោស, រឿងព្រះគុណមានថេរៈដីកានោះមែនណាស់ហើយ ខ្ញុំព្រះករុណាស្តាប់បានណាស់, ទានប្រោសរឿងខាងព្រះសង្ឃអស់ត្រឹមប៉ុណ្ណឹង ឬក៏នៅមានទៀត ខ្ញុំព្រះករុណាចង់ដឹង ច្រើនតទៅទៀត ។

ឧ. ឧទ័យ រឿងព្រះសង្ឃនោះនៅមានច្រើនណាស់ ដូចអាត្មាបានប្រាប់ឯងពីខាងដើមខ្លះមកហើយ, ព្រះសង្ឃក្នុងព្រះពុទ្ធសាសនានេះ លោកចែកជាពីប្រភេទគឺប្រភេទទី១ហៅថា **អរិយសង្ឃ** នោះលោកបានសម្រេចមគ្គផលតាំងពីសោតាបត្តិមគ្គរហូតដល់អរហត្តផល។ ប្រភេទទី២ ហៅថា **សម្មតិសង្ឃ** នោះជាបុថុជ្ជននៅប្រកបដោយ លោភៈ ទោសៈ មោហៈ ដូចជាគ្រហស្ថដែរ ប៉ុន្តែលោកខំប្រព្រឹត្តិប្រតិបត្តិតាមពុទ្ធឱវាទ ខំទូន្មានចិត្ត ខំហាត់ចិត្ត ដើម្បីឱ្យ

Websites: WatKhemaraRatanaram.org or WatKhmers.org



លោភៈ ទោសៈ មោហៈ ឃ្លាតស្រាលចេញ ពីសន្តានចិត្ត ។

ឱចៅ រឿងព្រះសង្ឃនោះ អាត្មាមិនអាចនឹងនិយាយពន្យល់ឯងក្នុងពេលនេះឱ្យចប់សព្វគ្រប់បានឡើយ ទុកជាខំនិយាយឱ្យច្រើនពេកទៅ ក៏ឯងមិនងាយនឹងត្រងត្រាប់ចាំបានសព្វគ្រប់ដែរ. ណ្ហើយប៉ុណ្ណឹងចុះ ប៉ុន្តែឯងត្រូវចាំកុំភ្លេចណា:. អាត្មាបានពន្យល់ឯងក្នុងថ្ងៃ ដំបូងពីរឿងព្រះពុទ្ធក្នុងថ្ងៃទី២ ពីរឿងព្រះពុទ្ធសាសនា ឬព្រះធម៌ ក្នុងថ្ងៃទី៣នេះ ពីរឿងព្រះសង្ឃទាំងបីនេះ ហៅថា **រតនត្រ័យ** ជាវត្ថុសម្រាប់គោរពនមស្ការបូជារបស់អ្នកកាន់ព្រះពុទ្ធសាសនាជានិច្ចនិរន្តរ៍ ។ អាត្មាសូមបញ្ចប់ត្រឹមប៉ុណ្ណេះហើយ ប៉ុន្តែឱ្យឯងរៀនពាក្យសម្រាប់នមស្ការព្រះសង្ឃផង អាត្មាសរសេរជាពាក្យកាព្យបទព្រហ្មគិតិដូចខាងក្រោមនេះ :

យើងខ្ញុំសូមបង្គំ សង្ឃឧត្តមលោកបរិសុទ្ធ
សន្តានចិត្តឃ្លាតផុត ពីកិលេសគ្រឿងសៅហ្មង ។
លោកជាទក្ខិណេយ្យ ស្រែបុណ្យថ្លៃនៃជនផង
ទាំងជាអ្នកចម្លង ជនទាំនាឱ្យដល់ត្រើយ ។
ព្រះសង្ឃគំពង់សត្វ លោកលះកាត់ទោសអស់ហើយ
មានចិត្តពុំកន្តើយ យោងខ្លួនហើយយោងគេផង ។
សូមឱ្យគុណព្រះសង្ឃ ជួយស្រោចស្រង់ឱ្យកន្លង
ឱ្យយើងខ្ញុំបានឆ្លង ដល់ត្រើយត្រាណក្សេមក្សាន្តហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org



ឧទ័យបានឆ្លើយតបថា ខ្ញុំព្រះករុណានិងមិត្រភ័ក្តិទាំងអស់គ្នា នឹងយកចិត្តទុកដាក់ទទួលឱវាទព្រះគុណ ដែលមេត្តាប្រៀនប្រដៅឱ្យយើងខ្ញុំព្រះករុណាស្គាល់ព្រះរតនត្រ័យយ៉ាងសង្ខេបនេះ តទៅយើងខ្ញុំព្រះករុណានឹងសិក្សាបណ្ដើរៗ ដើម្បីឱ្យបានចេះដឹងជ្រាលជ្រៅតទៅទៀត ។

ធ. អើ ល្អហើយ, ត្រូវខំប្រឹងរៀនសូត្រ ព្រមទាំងត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវតាមលំអានសីលធម៌របស់ឯងជាកុមារទាំងអស់គ្នាចុះ, ប៉ុន្តែមុននឹងចេញពីនេះទៅ, ត្រូវនាំគ្នាចម្លងប្រភេទនៃការសិក្សាសង្ខេបយកទៅរៀនទាំងអស់គ្នាក្នុងពេលដែលមានទំនេរ ។

ការសិក្សាដោយសង្ខេបមាន៤ប្រភេទគឺ :

១. វិជ្ជាសិក្សា រៀនចំណេះមានអក្សរសាស្ត្រជាដើម,

២. កម្មសិក្សា រៀនការងារ គឺរៀនឱ្យចេះធ្វើការ,

៣. ចរិយាសិក្សា រៀនរក្សាមារយាទ,

៤. កាយបរិហារសិក្សា រៀនរក្សារូបកាយ ឱ្យមានអនាម័យ សុខភាព ។

ឯងរាល់គ្នាត្រូវយល់ថា មនុស្សម្នាក់ៗ បើលុះតែមានការសិក្សាយ៉ាងតិចត្រឹម៤ប្រភេទប៉ុណ្ណេះ ទើបអាចតាំងខ្លួនឱ្យសមប្រកបតាមគោលបំណងរបស់ខ្លួនបាន ។

លុះកុមារទាំងអស់បានចម្លងប្រភេទការសិក្សារួចហើយ, លោក ធម្មធរៈ ក៏និយាយទៅកាន់កុមារទាំងនោះថា ឥឡូវដល់ពេលល្ងាចទៅផ្ទះហើយ, នាំគ្នាទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org



ផ្ទះចុះ ! សុខិតា ហោថ សូមឱ្យសុខសប្បាយទាំងអស់គ្នាណា:!

កុមារទាំងអស់នោះទទួលថា សាធុ! សាធុ!

ចប់

Websites: WatKhemaraRatanaram.org or WatKhmers.org

# បណ្តាំចំពោះយុវជន

## "អ្នកនៅវត្ត"

(បទពាក្យប្រាំពីរ)

ហៃអស់យុវជនអ្នកកំសត់ បើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ យប់ថ្ងៃហួសទៅឥតប្រយោជន៍
គួរអ្នកកុំភ្លេចវត្តលំនៅ ទោះអ្នកចេញទៅឆ្ងាយស្រឡាច
គួរដឹងគុណវត្តកុំបង្អោច ប្រយោជន៍នឹងផលផ្តល់ពុំខាន។
បើញាតិចោទសួរពីការរៀន ចំណេះរបៀនទាំងប៉ុន្មាន
អ្នកកុំនិយាយបង្វែងដាន ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
កុំពោលបង្អួតបួកដូចថី ថែងស្តីតាមត្រង់កុំបំភ្លាត់
បង្វែងបំផ្លើសបំភ្លេចវត្ត ក្រែងទោសទាញទាត់ឱ្យវិនាស។
បាយវត្តជាភោជន៍មានព្រលឹង គួរនឹករលឹកប្រឹងរៀស
រៀនសូត្រវិជ្ជាមានពោរពាស ដុះដាលដេរដាសកើតវិន័យ ។
បាយវត្តបាយផ្ទះដូចតែគ្នា ចំអែតអាត្មាមានជីវី
ឆ្អែតហើយរៀនសូត្រចេះខ្មិចខ្មី មុនីកើតមានដោយសារវត្ត ។
ចងចាំចេះចប់សព្វវិជ្ជា សាមគ្គីសាមគ្គាកុំភ្លាំងភ្លាត់
ស្មោះស្ម័គ្រចូលរួមធ្វើបដិវត្តន៍ ដើរត្រង់ប្រាកដសង្គមនិយម ។
ជាតិត្រូវការអស់អ្នកយុវជន កុំរួញទំរុនទទន់រលំ

Websites: WatKhemaraRatanaram.org or WatKhmers.org

